# THE EPILEPSY FOUNDATION

## OF VICTORIA INCORPORATED

REG.NO. A0022674D

### យើងជានរណា

Epilepsy Foundation of Victoria (មូលនិធិជម្ងឺស្កន់នៃរដ្ឋវិចតូរីយ៉ា) គឺជាអង្គការមានមូលដ្ឋានលើអតិថិជន ហើយមានគោលដៅដើម្បីឆ្លៀតយកគ្រប់ទាំងឱកាសលើកស្ទួយគុណភាពជីវិតនៃប្រជាជនដែលរស់នៅជាមួយជម្ងឺស្កន់។

បេសកកម្មរបស់យើងគឺផ្តល់កិច្ចបំរើដ៏ធំទូលាយមួយចំនួន ហើយងាយនឹងទទួលយក ព្រមទាំងកម្មវិធីទាំងឡាយដែលបំពេញទៅលើសេចក្តីត្រូវការផ្ទាល់ខ្លួន រវាងបុគ្គល សេដ្ឋកិច្ចសង្គម និងវប្បធម៌នៃអ្នកដែលរស់នៅជាមួយជម្ងឺស្កន់។

យើងមានជំនឿយ៉ាងមុតមាំនៅក្នុងតម្លៃសមធម៌ លទ្ធភាពប្រើប្រាស់ ការចូលរួម ភាពជាម្ចាស់ ការស៊ូប្តូរ ការដឹកនាំ និងការបញ្ចូលរបៀបថ្មីៗ។

### កន្លែងដែលយើងចាប់ផ្តើម

Epilepsy Foundation of Victoria បានបង្កើតឡើងក្នុងខែឧសភា ឆ្នាំ១៩៦៤ ដោយក្រុមមាតាបិតាដែលយកចិត្តទុកដាក់ទាំងឡាយដើម្បីផ្តល់ការផ្គត់ផ្គង់ និងព័ត៌មានទៅដល់ពលរដ្ឋវិចតូរីយ៉ាទាំងអស់ដែលបានប៉ះពាល់ដោយសារជម្ងឺស្កន់។

ពីដើមហៅថាការិយាល័យសំរាប់ជម្ងឺស្កន់រដ្ឋវិចតូរីយ៉ា ហើយអាទិភាពចម្បងគឺទីស្នាក់អាស្រ័យ បន្ទាប់ពីការបិទនៅក្នុងឆ្នាំ១៩៦៣ ដែលពេលនោះត្រូវបានគេស្គាល់ថាជាកុលសម្ព័ន្ធ Talbot សំរាប់អ្នកកើតជម្ងឺស្កន់។

ឈ្មោះរបស់អង្គការក៏បានប្តូរទៅ Epilepsy Foundation of Victoria នៅក្នុងឆ្នាំ១៩៧៨ ហើយក្នុងរយៈពេល៣ឆ្នាំបន្ទាប់មកក៏ឃើញមានការអភិវឌ្ឍន៏យ៉ាងលឿនរបស់ខ្លួន មានរួមទាំងការតែងតាំងភ្នាក់ងារពិគ្រោះផ្នែកវេជ្ជសាស្ត្រ ហើយនិងការបង្កើតឲ្យមានក្រុមប្រឹក្សាវេជ្ជសាស្ត្រ។

ពេញទូទាំងអម្លុងឆ្នាំ១៩៩០ ហើយចូលមកដល់សតវត្សទី២១ មូលនិធិនឹងបន្តធ្វើការឆ្ពោះទៅរកគោលដៅដើម្បីលើកស្ទួយគុណភាពនៃជីវិតសំរាប់ប្រជាជនដែលរស់នៅជាមួយជម្ងឺស្កន់ ហើយដើម្បីកែលំអនូវការដឹងឮ និងការយល់ដឹងរបស់សហគមន៏ផងដែរ។

## កិច្ចបំរើរបស់យើងមានរួមទាំង:

### ព័ត៌មានស្តីអំពីជម្ងឺស្កន់

យើងផ្តល់កិច្ចបំរើផ្នែកព័ត៌មានដ៏ធំទូលាយបំផុតក្នុងប្រទេសអូស្ត្រាលីមានរួមទាំងសៀវភៅ ចុល្លលិខិត និងសន្លឹកព័ត៌មានមួយចំនួនធំ។ ខ្សែវីឌីអូ ឌីវីឌី ហើយនិងវត្ថុឯទៀតមានសំរាប់បុគ្គលម្នាក់ៗដែលមានជម្ងឺស្កន់ គ្រួសារ មិត្តភក្តិ អ្នកមើលថែ ស្ថាប័នផ្តល់កិច្ចបំរើ និយោជក ហើយនិងសហគមន៍ទូទៅ។ ព័ត៌មានក៏មានផ្តល់ផងដែរជាភាសាសហគមន៍មួយចំនួន។

### ឱវាទណែនាំស្ទាត់ជំនាញ – មធ្យោបាយដែលមានជំនាញការច្រើន

ក្រុមផ្តល់ឱវាទណែនាំរបស់យើងយល់អំពីជម្ងឺស្កន់ថាជាលក្ខណៈរោគមួយ ហើយអាចផ្តល់ឱវាទណែនាំលើវិធីព្យាបាលដ៏មានប្រសិទ្ធិភាពមួយចំនួន។ បុគ្គលម្នាក់ៗ មាតាបិតា និងគ្រួសារថ្មីៗដែលបានធ្វើរោគវិនិច្ឆ័យអាចទទួលការផ្គត់ផ្គង់ជាបន្តបន្ទាប់ ក្នុងអម្លុងពេលនៃការកែសំរួលនេះ។ សមាជិកបុគ្គលិកដែលមានវិជ្ជាជីវៈក៏មាននៅប្រចាំការផងដែរ ដើម្បីជួយក្នុងបញ្ហាទាំងឡាយដូចជាគោលការណ៏ថ្មីៗស្តីអំពីការបើកបរ ការប្រកាន់រើសអើងនៅទីកន្លែងធ្វើការ យុទ្ធសាស្ត្រជីវភាពរស់នៅ ជំនួយនៅតាមថ្នាក់រៀន ហើយនិងការផ្គត់ផ្គង់សំរាប់មាតាបិតា និងអ្នកមើលថែ។

### បណ្ណាល័យ

បណ្ណាល័យរបស់មូលនិធិពេញចិត្តនឹងការប្រមូលនៃធនធានជម្ងឺស្កន់ជាក់លាក់យ៉ាងល្អៗក្នុងប្រទេសអូស្ត្រាលី។ មានចំណងជើងសៀវភៅច្រើនជាង ១៥០០មុខ ខ្សែវីឌីអូ និងឌីវីឌីផ្សេកៗ ការប្រមូលព្រឹត្តិបត្រពេញលេញស្តីអំពីជម្ងឺស្កន់ និងឯកសារព័ត៌មានថ្មីៗយ៉ាងធំទូលាយទាក់ទិននឹងជម្ងឺស្កន់ និងបញ្ហាទាំងឡាយទាក់ទិននឹងការរស់នៅជាមួយជម្ងឺស្កន់។

ក្នុងអម្លុងពេលម៉ោងបណ្ណាល័យបើកធ្វើការ (ម៉ោង៩ព្រឹក – ម៉ោង៥ល្ងាច ថ្ងៃច័ន្ទ – ថ្ងៃសុក្រ) លោកអ្នកត្រូវបានស្វាគមន៍ឲ្យអញ្ជើញមកការិយាល័យធំរបស់មូលនិធិនៅតំបន់ Camberwell ហើយស្វែងរកព័ត៌មានចេញពីសម្ភារៈឯកសារប្រមូលរបស់យើង។ លោកអ្នកក៏អាចប្រើប្រាស់បណ្ណាល័យផងដែរក្នុងអម្លុងពេលសិក្ខាសាលា កម្មវិធីពិភាក្សា និងការប្រជុំនៅឯមូលនិធិ ហើយធនធានរបស់យើងមានផ្តល់សំរាប់គ្រប់កំរិតចាប់ពីកុមារ ទៅមនុស្សធំទង់។ សមាជិកមូលនិធិមានសិទ្ធិខ្ចីសៀវភៅ និងខ្សែវីឌីអូ។

## ធនធានសំរាប់ទិញ

សៀវភៅសំរាំងមួយចំនួនមានផ្តល់តាមរយៈហាងលក់ធនធានរបស់មូលនិធិ ហើយមានអត្តសញ្ញាណគ្រឿងអលង្ការវេជ្ជសាស្ត្រ ប្រដាប់ផ្តល់ថ្នាំពេទ្យជាដើម។ល។

## ការគ្រប់គ្រងករណីផ្ទាល់ខ្លួនសំរាប់ដំណោះស្រាយដែលស្មុគស្មាញ ហើយមានរយៈពេលវែង

អ្នកប្រឹក្សារបស់យើងទាក់ទិនក្នុងបែបជាអ្នកដឹកនាំ ឬផ្គត់ផ្គង់អ្នកប្រឹក្សាជាមួយភ្នាក់ងារឯទៀត និងបុគ្គលិកផ្នែកវេជ្ជសាស្ត្រនៅក្នុងការគ្រប់គ្រងស្ថានការណ៏រោគដែលស្មុគស្មាញខ្លាំងមួយចំនួន។

## ការគាំទ្រ – ផ្ទាល់ខ្លួន រដ្ឋ និងក្នុងប្រទេស

មានមនុស្សជាច្រើនដែលកើតជម្ងឺស្កន់ ត្រូវទ្រាំទ្រជាមួយនឹងការលំអៀង ហើយមានការយល់ខុសអំពីការរស់នៅប្រចាំថ្ងៃរបស់ខ្លួន។ យើងធ្វើការជាមួយនិយោជក អង្គការ រដ្ឋាភិបាល និងបុគ្គលម្នាក់ៗដើម្បីផ្លាស់ប្តូរស្ថានការណ៏ទាំងនេះ។

## ការអប់រំសហគមន៍

យើងផ្តល់កិច្ចបំរើសមរម្យ ហើយជាញឹកញយរៀបចំផ្ទាល់ពិសេស មានរួមទាំងការនិយាយទៅកាន់អង្គការសហគមន៍ ក្រុមអង្គការសុខភាព និងសុខុមាលភាព អាជីវកម្ម ស្ថាប័នអប់រំ សិស្ស ស្ថាប័នរដ្ឋ និងក្រុមទាំងឡាយទៀត។

## សិក្ខាសាលា

សេចក្តីត្រូវការនៃប្រជាជនដែលកើតជម្ងឺស្កន់ និងគ្រួសាររបស់គេគឺខុសគ្នាស្របទៅតាមកាលៈទេសៈរបស់គេ និងប្រភេទនៃជម្ងឺស្កន់របស់គេ។ យើងរៀបចំសិក្ខាសាលាដោយមានអ្នកថ្លែងសន្ទរកថាឯកទេសដើម្បីជួយដល់អស់អ្នកដែលរស់នៅជាមួយ ហើយមើលថែអ្នកកើតជម្ងឺស្កន់ ព្រមទាំងឲ្យគេបានដឹងព័ត៌មានទាន់ពេលផងដែរអំពីការស្រាវជ្រាវជាបន្តបន្ទាប់នៅក្នុងការដឹងយល់ និងការព្យាបាលជម្ងឺស្កន់។

## កម្មវិធីហ្វឹកហ្វឺនឯកទេស

មូលនិធិបានបង្កើតកម្មវិធីហ្វឹកហ្វឺនដែលរដ្ឋទទួលស្គាល់ជាផ្លូវការ វគ្គ និងសិក្ខាសាលា ជាញឹកញយធ្វើរួមជាមួយភ្នាក់ងាររដ្ឋាភិបាលដើម្បីចាត់ចែងទៅដល់អ្នកវិជ្ជាជីវៈផ្នែកសុខភាព ប្រជាជនដែលកើតជម្ងឺស្កន់ និងអ្នកមើលថែរបស់ខ្លួន។ សិក្ខាសាលាមានគោលដៅដើម្បីគ្របដណ្តប់លើបញ្ហាមួយចំនួនទាក់ទិននឹងប្រជាជនដែលកើតជម្ងឺស្កន់ និងគ្រួសាររបស់ខ្លួន ដូចជាការដឹងយល់អំពីជម្ងឺស្កន់ កត្តាជីវភាពរស់នៅ ការវះកាត់ ការចិញ្ចឹមកូនដែលកើតជម្ងឺស្កន់ និងបញ្ហាភេទជាក់លាក់ទាំងឡាយ។

## ព្រឹត្តិការណ៏ពិសេស

ទាំងនេះមានរួមទាំង Trivia Challenge (ការប្រកួតប្រជែងគ្នាក្នុងរឿងកំប៉ិកកំប៉ុក) សំរាប់សាលារៀនរដ្ឋវិចតូរីយ៉ា ការរៃអង្គាសប្រាក់ និងព្រឹត្តិការណ៏សហគមន៍ឯទៀត ការប្រជុំសហគមន៍ និងក្រុមពិភាក្សា។

## *Epilink*

ជាញឹកញយដែលកំណត់ដោយការពុំមានសមត្ថភាពដើម្បីធ្វើដំណើរ កម្មវិធីតភ្ជាប់ទូរស័ព្ទនេះអនុញ្ញាតឲ្យអតិថិជនផ្តល់ការផ្គត់ផ្គង់សំរាប់គ្នាទៅវិញទៅមក និងការប្រកបរវាងគ្នានឹងគ្នានៅក្រោមការណែនាំដោយវិជ្ជាជីវៈនៃអ្នកប្រឹក្សា។

## Epinet – ធនធានអ៊ិនធើណិតផ្នែកជម្ងឺស្កន់

មូលនិធិបានបង្កើតវ៉ិបសាយជម្ងឺស្កន់ទីមួយក្នុងប្រទេសអូស្ត្រាលី (www.epinet.org.au) ហើយមានព័ត៌មានអំពីជម្ងឺស្កន់យ៉ាងធំធេង រៀបចំក្រុមពិភាក្សាតាមអ៊ិនធើណិត ការទាក់ទងតាមអ៊ីម៉េលជាមួយអ្នកប្រឹក្សា ហើយដាក់ភ្ជាប់ទៅនឹងធនធានផ្នែកជម្ងឺស្កន់ជាច្រើនពេញទូទាំងពិភពលោក។

## ការបោះជំរុំកំសាន្តសំរាប់ប្រជាជនដែលមានជម្ងឺស្កន់ និងគ្រួសាររបស់ខ្លួន

ការបោះជំរុំប្រចាំឆ្នាំទាំងនេះផ្តល់សំរាប់បុគ្គលម្នាក់ៗនូវឱកាសដើម្បីទទួលបទពិសោធន៍ដែលយើងជាច្រើននាក់ពុំសូវចាប់អារម្មណ៍។ ចំពោះអ្នកខ្លះ ការទៅបោះជំរុំសំរាប់មនុស្សជំទង់ នេះគឺជាលើកដំបូងដែលគេនៅឆ្ងាយពីគ្រួសាររបស់គេ។ ការបោះជំរុំសំរាប់គ្រួសារ ផ្តល់នូវបរិដ្ឋានមួយដែលមាតាបិតា បងប្អូន និងកុមារដែលមានជម្ងឺស្កន់អាចសប្បាយរីករាយនឹងពេលវេលារបស់គេឆ្ងាយពីផ្ទះ ជាមួយអ្នកឯទៀតដែលយល់ដឹងយ៉ាងណាខ្លះអំពីការរស់នៅជាមួយជម្ងឺស្កន់នៅក្នុងគ្រួសារ។

## ទីស្នាក់អាស្រ័យ

ជាសំខាន់យ៉ាងខ្លាំងសំរាប់គិលានដ្ឋានព្យាបាលជម្ងឺស្កន់ធំៗ មូលនិធិផ្តល់ទីស្នាក់អាស្រ័យរយៈពេលខ្លីសំរាប់ដៃគូរ និងគ្រួសារដែលនៅមន្ទីរពេទ្យ ហើយកំពុងទទួលការធ្វើតេស្ត ការឃ្លាំពិនិត្យជម្ងឺស្កន់ ការវះកាត់ខួរក្បាល និងការវះកាត់ឯទៀត។

## ការផ្តត់ផ្គង់នៅតាមគិលានដ្ឋាន និងការទៅពិនិត្យតាមមន្ទីរពេទ្យ

អ្នកប្រឹក្សារបស់យើងធ្វើការយ៉ាងជិតស្និទ្ធជាមួយអ្នកវិជ្ជាជីវៈផ្នែកសុខភាព មានរួមទាំងការទៅគិលានដ្ឋានជម្ងឺស្កន់ និងគិលានដ្ឋានព្យាបាលរោគប្រកាច់លើកដំបូង។ គេក៏ទៅពិនិត្យអ្នកជម្ងឺនៅតាមមន្ទីរពេទ្យធំៗផងដែរ។

## ការស្រាវជ្រាវ

EFV ទទួលអនុវត្តការស្រាវជ្រាវនៅក្នុងបញ្ហាទាំងឡាយ ដែលភាគច្រើនប៉ះពាល់ដល់ជីវិតរបស់អ្នកមានជម្ងឺស្កន់ និងគ្រួសាររបស់ខ្លួន។ គោលដៅរបស់យើងគឺដើម្បីកែលំអជីវិតរស់នៅរបស់ប្រជាជនដែលកើតជម្ងឺស្កន់ ដោយផ្តល់ការស្រាវជ្រាវដែលមានមូលដ្ឋានលើការជាក់ស្តែងទៅដល់អ្នករៀបចំគោលការណ៍ និងអ្នកវិជ្ជាជីវៈផ្នែកសុខភាព។ អស់អ្នកដែលយកចិត្តទុកដាក់នៅក្នុងការចូលរួមការស្រាវជ្រាវ ដូចជាក្រុមអ្នកវាស់ស្ទង់ និងក្រុមអ្នកយកចិត្តទុកដាក់ អាចចូលរួមនៅក្នុងការស្រាវជ្រាវរបស់យើង ដោយទទួលយកពាក្យបំពេញមួយពីការិយាល័យទទួលភ្ញៀវនៅ Epilepsy Foundation។

# សិទ្ធិ និងការទទួលខុសត្រូវ

## អ្វីដែលលោកអ្នកអាចរំពឹងទុកអំពីយើង:

- ត្រូវបានគេព្យាបាលដោយយកចិត្តទុកដាក់ យោគយល់ គោរព ហើយមានភាពថ្លៃថ្នូរគ្រប់ពេលវេលា
- ទទួលគុណភាពនៃកិច្ចបំរើពីបុគ្គលិកដែលបានទទួលការហ្វឹកហ្វឺន ដែលទទួលស្គាល់ទៅលើសេចក្តីត្រូវការរបស់មនុស្សម្នាក់ៗ
- ថាព័ត៌មាននឹងត្រូវបានចាត់ចែងក្នុងលំនាំច្បាស់លាស់ ហើយមានការដឹងយល់
- ថាលោកអ្នកនឹងទទួលកិច្ចបំរើដែលមិនប្រកាន់រើសអើងលើពូជសាសន៍ សាសនា ជំនឿនយោបាយ ភេទ អាយុ និយមភេទ ពិការភាព ទីកន្លែង ភាសា ឬស្ថានការណ៍សុខភាព
- ថាលោកអ្នកអាចបញ្ចេញនូវកង្វល់ណាមួយអំពីកិច្ចបំរើដែលលោកអ្នកបានទទួលពីយើង ដោយគ្មានការភ័យខ្លាចទៅលើការខូចនូវផលប្រយោជន៍ណាមួយ។

## អ្វីដែលយើងអាចរំពឹងទុកអំពីលោកអ្នក:

- ជួយយើងដោយផ្តល់នូវព័ត៌មានពិតត្រង់ ហើយពេញលេញអំពីបញ្ហាជម្ងឺស្កន់របស់លោកអ្នក និងបញ្ហាទាក់ទិនឯទៀត
- ថាលោកអ្នករក្សាពេលណាត់ជួបរបស់លោកអ្នក ឬផ្តល់ដំណឹងមកយើងប្រសិនបើលោកអ្នកបានពន្យា ឬត្រូវលុបចោលពេលណាត់ជួប
- គោរពទៅលើកិច្ចព្រមព្រៀងណាមួយដែលបានធ្វើឡើងរវាងលោកអ្នក និងអ្នកប្រឹក្សាកិច្ចបំរើអតិថិជនរបស់លោកអ្នក
- ប្រព្រឹត្តចំពោះបុគ្គលិក និងអ្នកឯទៀតដោយភាពគួរសម ហើយគោរព។

## ភាពជាឯកជន និងការរក្សាទុកជាសម្ងាត់

ក្នុងភាពជាស្ថាប័នផ្តល់កិច្ចបំរើពិការភាពដែលចុះឈ្មោះស្របច្បាប់ យើងនឹងបំពេញមុខការដោយអស់អំពីចិត្តរបស់យើងដើម្បីប្រាកដឲ្យបានច្បាស់ថាព័ត៌មានណាមួយដែលយើងប្រមូលបានអំពីលោកអ្នក ត្រូវបានរក្សាទុកដោយសន្តិសុខ ហើយនឹងត្រូវបានយកប្រើដោយមានការគោរពស្របទៅតាម (Commonwealth) Privacy Act 1988 (ច្បាប់ឯកជន (សហព័ន្ធ) ឆ្នាំ១៩៨៨) និង (Victorian) Information Privacy Act 2000 (ច្បាប់ព័ត៌មានឯកជន (វិចតូរីយ៉ា) ឆ្នាំ២០០០)។

## ដំណើរការប្តឹងតវ៉ា

Epilepsy Foundation of Victoria សូមស្វាគមន៍យោបល់ឆ្លើយតបពីប្រជាជនដែលប្រហែលជាមានបញ្ហា កង្វល់ ឬការត្អូញត្អែរណាមួយអំពីកិច្ចបំរើដែលគេបានទទួលពីយើង។ ការនេះផ្តល់មកឲ្យយើងនូវឱកាសដើម្បីពិនិត្យឡើងវិញដោយមិនលំអៀងអំពីកិច្ចបំរើរបស់យើង ហើយអនុវត្តការកែលំអ ពេលណាចាំបាច់។

ប្រសិនបើមានជនណាម្នាក់កើតជម្ងឺស្កន់ សមាជិកគ្រួសារ អ្នកមើលថែ ឬស្ថាប័នផ្តល់កិច្ចបំរើ មានអារម្មណ៍ថាគេបានទទួលកិច្ចបំរើតិចជាងកំរិតគ្រប់គ្រាន់ ពីសមាជិកណាមួយនៃក្រុមបុគ្គលិកកិច្ចបំរើអតិថិជនរបស់យើង យើងសូមលើកទឹកចិត្តឲ្យគេនាំយកបញ្ហានោះទៅនាយកចាត់ចែងកិច្ចបំរើអតិថិជន។ ការប្តឹងតវ៉ានោះអាចធ្វើឡើយដោយផ្ទាល់មាត់ ឬសរសេរ ហើយអាចធ្វើផ្ទាល់ដោយជនដែលមានកង្វល់នោះ ឬដោយនរណាម្នាក់ដែលបានជ្រើសតាំងដោយជននោះ។ ជាការល្អ គេគួរទាក់ទងជាមួយយើងឲ្យបានឆាប់ដែលអាចធ្វើទៅបាន ក្រោយពីកើតមានហេតុការណ៍នោះ។ ប្រសិនបើគេពុំអាចដោះស្រាយបញ្ហានោះក្នុងកំរិតនេះបានទេ នោះគេនឹងបញ្ជូនទៅប្រធាននាយកប្រតិបត្តិ។

ប្រសិនបើ Epilepsy Foundation of Victoria មិនអាចដោះស្រាយបណ្តឹងរបស់លោកអ្នកបានទេ លោកអ្នកអាចជ្រើសរើសទាក់ទងជាមួយ Disability Services Commissioner (គណៈកម្មការកិច្ចបំរើពិការភាព) នៅ Level 3, 456 Lonsdale Street, Melbourne, 3000។ ទូរស័ព្ទលេខៈ 1800 677 342 ឬ 1300 728 187 (ទូរស័ព្ទក្នុងតំបន់) TTY: 1300 726 563 ទូរសារៈ 03 9603 8310 វ៉ិបសាយៈ http://www.odsc.vic.gov.au

**THE EPILEPSY FOUNDATION**

**OF VICTORIA INCORPORATED**

REG.NO. A0022674D

សមាជិកវិចតូរីយ៉ានៃ **Epilepsy Australia** – អង្គការជម្ងឺស្កន់កំពូលដឹកនាំដោយអតិថិជននៃប្រទេសអូស្ត្រាលី

818 Burke Road, Camberwell, Victoria, Australia, 3124 *ទូរស័ព្ទៈ* 03 9805 9111 ឬ 1300 852853

*ទូរសារៈ*03 9882 7159 *អ៊ីម៉េលៈ* epilepsy@epilepsy.asn.au *វ៉ិបសាយៈ* http://www.epinet.org.au

ការិយាល័យប្រចាំភូមិភាគ **Grampians:** The Cooinda Centre, 10 Learmouth Road, Wendouree, Ballarat, 3355

*ទូរស័ព្ទៈ* 03 5338 1277

**Barwon /** ការិយាល័យប្រចាំភូមិភាគនិរតីៈ Barwon Design Park, 400 Pakington Street, Newtown, Geelong, 3220

*ទូរស័ព្ទៈ*03 5223 1645

*These translations funded by The Ian Potter Foundation &*
*The Helen Macpherson Smith Trust*